01568826

**Declassified to Public**
**28 November 2018**

D262

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 04-May-2018, 10:28
CMS/CFO: Phok Chanthan

**សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចដាក់ដីកាសម្រេចពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នាចូលក្នុងសំណុំរឿង ០០៣

---

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម

Michael KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

ឡោ ជុនធី

សំ សុគង់

ស៊ិន ស៊ីវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Yiqiang LIU
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត(“ស.ច.ស”) នៅក្នុងសំណុំរឿងនេះបានចុះកំណត់ហេតុនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ មេធាវីការពារក្តី អោ អាន នៅក្នុងសំណុំរឿង ០០៤/២ បានដាក់*សំណើសុំការបញ្ជាក់បំភ្លឺ* ពាក់ព័ន្ធនឹងការដែល សហព្រះរាជអាជ្ញា អាចដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែកពីគ្នា(“សំណើសុំការបញ្ជាក់បំភ្លឺ”)[1]។

៣. នៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស បានចេញដីកាសម្រេចលើសំណើសុំការបញ្ជាក់បំភ្លឺ (“ដីកាសម្រេចលើការបញ្ជាក់បំភ្លឺ”)[2]។

៤. នៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ មេធាវីការពារក្តី អោ អាន នៅក្នុងសំណុំរឿង ០០៤/២ បានដាក់*សំណើបន្ទាន់សុំឯកសារដែលពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នា* (“សំណើសុំឯកសារខ្វែងយោបល់គ្នា”)[3]។

៥. នៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស បានចេញដីកាសម្រេចលើសំណើសុំឯកសារខ្វែងយោបល់គ្នា (“ដីកាសម្រេចលើសំណើសុំឯកសារខ្វែងយោបល់គ្នា”)[4]។

៦. ដីកាសម្រេចលើការបញ្ជាក់បំភ្លឺ និងដីកាសម្រេចលើសំណើសុំឯកសារខ្វែងយោបល់គ្នា ក៏បានជូនដំណឹងផងដែរទៅភាគីសំណុំរឿង ០០៤ ហើយបានដាក់ចូលក្នុងសំណុំរឿង ០០៤ ពីព្រោះថា ដីកាសម្រេចទាំងនោះជូនដំណឹងភាគីអំពីការយល់ឃើញរបស់ ស.ច.ស ជាទូទៅអំពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ការសម្ងាត់នៃករណីខ្វែងយោបល់គ្នា និងការ

---

[1] សំណុំរឿង ០០៤/២ ឯកសារ D353 *សំណើសុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧។

[2] សំសំណុំរឿង ០០៤/២ ឯកសារ D353/1 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំការបញ្ជាក់បំភ្លឺ* ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧។

[3] សំណុំរឿង ០០៤/២ ឯកសារ D355 *សំណើបន្ទាន់សុំឯកសារដែលពាក់ព័ន្ធទៅនឹងការខ្វែងយោបល់គ្នា* ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧។

[4] សំណុំរឿង ០០៤/២ ឯកសារ D355/1 *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា* ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧។

ចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា។ ស្រដៀងគ្នានេះដែរ ខ្ញុំយល់ឃើញថា ដីកាសម្រេចទាំងនោះ នឹងមានប្រយោជន៍ដល់ភាគីសំណុំរឿង ០០៣ ហេតុនេះ ត្រូវដាក់ចូលក្នុងសំណុំរឿង ០០៣។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

៧. **បង្គាប់ឲ្យ** ក្រឡាបញ្ជី ដាក់សំណៅសម្ងាត់នៃដីកាសម្រេចលើការបញ្ចាក់បំភ្លឺ និងដីកាសម្រេចលើសំណើសុំឯកសារខ្វែងយោបល់គ្នា ចូលក្នុងសំណុំរឿង ០០៣។

ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេស ដោយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**